00698278

លេខ/No: D11/2/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 003/20-11-2008

លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 003/07-09-2009-ECCC-OCIJ

# សៀវភៅចុះបណ្ដឹងឧទ្ធរណ៍
# Record of Appeals
# Registre des appels

ឆ្នាំពីរពាន់ដប់មួយ ខែឧសភា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងពីរនិងសាមសិបប្រាំមួយនាទីរសៀល

យើង លី ច័ន្ទតុលា ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

បានទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនទាន់ទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត សំ សុគង់ និង Lyma NGUYEN

ប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី Rob Hamill ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ ដែលត្រូវបានជូនដំណឹងតាមរយៈការប្រគល់ផ្ទាល់ដៃកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 05 / 2011
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

ក្រឡាបញ្ជី
Greffiers

LY Chantola

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00698279

ឯកសារ: D11/2/4

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 18-May-2011, 08:29
CMS/CFO: Uch Arun

**ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍**
**ដាក់ជូនទៅ សហចៅក្រមស៊ើបអង្កេត**

ដោយអនុលោមទៅតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង (ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ និងសារណាស្តីពីបណ្តឹងឧទ្ធរណ៍ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាស្តីពីភាពអាចទទួលយកបាននៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Rob HAMILL (ម្ចាស់បណ្តឹងឧទ្ធរណ៍) (លេខឯកសារ D11/2/3) ចុះថ្ងៃទី២៩ មេសា ២០១១ និងត្រូវបានទទួលដោយម្ចាស់បណ្តឹងឧទ្ធរណ៍គឺលោក Rob HAMILL តាមរយៈសំបុត្រប្រៃសណីយ៍ នៅឯកអាស័យដ្ឋានក្នុងប្រទេស New Zealand នៅថ្ងៃទី១២ ឧសភា ២០១១។

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថា ការបដិសេធសម្រាប់សំណុំរឿង០០៤ ក៏ត្រូវបានធ្វើឡើងហើយដែរ នៅក្នុងឯកសារលេខ D5/2/3។ ទោះបីយ៉ាងណាក៏ដោយ សហមេធាវីរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍មិនទាន់ត្រូវបានអនុញ្ញាតឲ្យចូលមើលសំណុំរឿង ០០៣ និង ០០៤ ឡើយ ហើយនៅថ្ងៃទី ១២ ឧសភា ២០១១ ដីកាស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានជូនដំណឹង ឬបានទទួលដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ឬមេធាវីរបស់គាត់ឡើយ[1]។

ការជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍នេះគឺធ្វើជាការជូនដំណឹងអំពីគោលបំណងក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាស្តីពីភាពអាចទទួលយកបានទូពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D11/2/3 និង D5/2/3 (ប្រសិនបើ/នៅពេលត្រូវបានទទួលនៅពេលក្រោយ)[2]។

ចុះហត្ថលេខាដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

| | |
|---|---|
| **លោក សំ សុគង់** | Lyma NGUYEN |
| សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី | សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី |

ធ្វើនៅថ្ងៃទី១២ ឧសភា ២០១១

---

[1] ទោះបីយ៉ាងណាក្តី ដីកាស្តីពីភាពអាចទទួលយកបានក្នុងសំណុំរឿង ០០៣ មានប្រយោគមួយនៅចុងក្រោយ ដែលនិយាយថា សហចៅក្រមស៊ើបអង្កេត " បដិសេធ " ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ និងសំណើពាក់ព័ន្ធផ្សេងទៀត។

[2] បណ្តឹងឧទ្ធរណ៍ទៅនឹងការបដិសេធនៅក្នុងសំណុំរឿង០០៣ និង ០០៤ នឹងត្រូវបានធ្វើនៅក្នុងសារណាតែមួយ។